ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# សេចក្តីជូនដំណឹងស្តីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ

**អគ្គនាយកដ្ឋានពន្ធដារ** ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាចំនួន ៨០ រូប
ដើម្បីបំពេញការងារជាបុគ្គលិក **ផ្នែកបញ្ចូលទិន្នន័យ (Data Entry Staff)** នៅអគ្គនាយកដ្ឋានពន្ធដារ។

**<u>លក្ខខណ្ឌដែលត្រូវជ្រើសរើស</u>**

-ត្រូវមានកម្រិតវប្បធម៌ បរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល
-ត្រូវមានជំនាញផ្នែកកុំព្យូទ័រច្បាស់លាស់ ជាពិសេសកម្មវិធី MS Word, MS Excel, Internet, E-mail។ល។
-អាចវាយអត្ថបទទាំងភាសាខ្មែរ និងភាសាអង់គ្លេស ក្នុងល្បឿនពី ៧០ ទៅ ១០០ ពាក្យ ក្នុងមួយនាទី
-ត្រូវចេះអាន និងសរសេរភាសាខ្មែរ ភាសាអង់គ្លេសបានល្អ
-ត្រូវមានបទពិសោធន៍ការងារផ្នែកបញ្ចូលទិន្នន័យ (Data Entry) យ៉ាងតិច ១ឆ្នាំ
-ប្រសិនបើមានជំនាញផ្នែករដ្ឋបាលបន្ថែម កាន់តែប្រសើរ
-ត្រូវមានទំនាក់ទំនងល្អជាមួយក្រុមការងារ និងអង្គភាព
-ត្រូវមានភាពអំណត់ និងធ្វើការបានក្រោមសម្ពាធ
-ត្រូវមានការទទួលខុសត្រូវខ្ពស់ចំពោះការងា និងគោរពក្រមសីលធម៌ វិជ្ជាជីវៈបានល្អ
-មិនត្រូវប្រើប្រាស់ព័ត៌មានផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេសទិន្នន័យរបស់អ្នកជាប់ពន្ធយកទៅបម្រើផលប្រយោជន៍ក្នុងគោលដៅផ្សេង ដោយមិនមានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារឡើយ
-បេក្ខនារី នឹងត្រូវបានផ្តល់អាទិភាព

**<u>ព័ត៌មាននៃការដាក់ពាក្យសុំបម្រើការងារ</u>**

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ និងមានសមត្ថភាពដូចរៀបរាប់ខាងលើ សូមទាញយកទម្រង់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារ និងប្រវត្តិរូបសង្ខេប តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាន www.tax.gov.kh/recruit យកទៅបំពេញដោយកុំព្យូទ័រ បន្ទាប់មកត្រូវផ្ញើមកវិញ ដោយមានបិទរូបថតបច្ចុប្បន្ន (រូបថតដែលថតថ្មី មិនលើសរយៈពេល បីខែ) និងភ្ជាប់មកជាមួយនូវ ច្បាប់ថតចម្លងសញ្ញាបត្រដែលមាន ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ តាមរយៈ E-mail ដែលមានអាសយដ្ឋានៈ de80@tax.gov.kh ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋានៈ អាគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
ទូរស័ព្ទលេខៈ ០២៣ ៨៨៦ ៧២៤ រៀងរាល់ម៉ោងធ្វើការ
កាលបរិច្ឆេទឈប់ទទួលពាក្យ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ១៧:០០ នាទី។

Collection by VCAT Professional Consultant

អគ្គនាយកដ្ឋានពន្ធដារ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# សេចក្តីជូនដំណឹងស្តីពី

## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ

**អគ្គនាយកដ្ឋានពន្ធដារ** ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជា **ជំនួយការបច្ចេកទេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Support Technician)** ចំនួន ២០ រូប ដើម្បីបម្រើការងារគាំទ្រដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅក្នុងអគ្គនាយកដ្ឋានពន្ធដារដោយផ្ទាល់ និងនៅតាមបណ្តាសាខាពន្ធដារខេត្ត ដែលជាសេនាធិការរបស់នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងការធានា ផ្តល់នូវសេវាបច្ចេកទេសឱ្យទាន់ពេលវេលា។

### ភារកិច្ចទទួលខុសត្រូវសំខាន់ៗ

-គាំទ្រដល់អ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់ នៃអគ្គនាយកដ្ឋានពន្ធដារ

-គាំទ្របច្ចេកទេសក្នុងការរៀបចំ ដំឡើងហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន របស់អគ្គនាយកដ្ឋានពន្ធដារ រួមមាន៖ ប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធអ៊ីនធឺណែត បណ្តាញកុំព្យូទ័រ បណ្តាញអគ្គិសនីបន្ទាប់បន្សំ និងឧបករណ៍បច្ចេកទេសផ្សេងៗទៀត

-គាំទ្របច្ចេកទេស ដំឡើងនិងថែទាំ បរិក្ខារកុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនស្កេន ម៉ាស៊ីនស្កេនម្រាមដៃ កាមេរ៉ាសុវត្ថិភាព និងឧបករណ៍បច្ចេកវិទ្យាព័ត៌មានផ្សេងៗ

-គាំទ្របច្ចេកទេសក្នុងការដោះស្រាយបញ្ហាដោយផ្ទាល់ និងតាមរយៈការគាំទ្របច្ចេកទេសប្រព័ន្ធពីស្នាក់ការកណ្តាល

-គាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់តាមរយៈការផ្តល់ឯកសារ ឬសៀវភៅណែនាំពីរបៀបប្រើប្រាស់ ការពន្យល់ និងស្វែងរកដំណោះស្រាយល្អបំផុតដល់អ្នកប្រើប្រាស់ ឬទំនាក់ទំនងមកក្រុមការងារ នៅស្នាក់ការកណ្តាល ដើម្បីជួយគាំទ្រ បច្ចេកទេសបន្ថែម

-ត្រូវមានមនសិការខ្ពស់ក្នុងការជួយជ្រោមជ្រែង ថែរក្សា ការពារសម្ភារ ឲ្យប្រើប្រាស់បានយូរអង្វែង

-ត្រូវមានភាពអំណត់ ព្យាយាមដោះស្រាយបញ្ហាឲ្យទាន់ពេលវេលា

-ត្រូវធ្វើបញ្ជីភ័ស្តុភារសម្រាប់ការគ្រប់គ្រងសម្ភារបច្ចេកទេសផ្សេងៗក្នុងសាខានីមួយៗ

-ត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃមកថ្នាក់លើ

### សមត្ថភាព

-ផ្តល់អាទិភាពទៅលើអ្នកមានភាពទំនាក់ទំនងល្អ និងឆ្លើយតបរាល់សំណើ

-មានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងអគ្គិសនីបន្ទាប់បន្សំ

-មានចំណេះដឹងទាក់ទងនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធនានា

-មានជំនាញដោះស្រាយបញ្ហារបស់កុំព្យូទ័រ និងបណ្តាញ

-មានជំនាញវិភាគ និងដោះស្រាយបញ្ហា យ៉ាងរាងវៃ ឆាប់រហ័ស

-មានចំណេះដឹង និងការអនុវត្តនីតិវិធី និងគោលនយោបាយ

-មានចំណេះដឹងនៃការគ្រប់គ្រង ការប្រើប្រាស់ប្រព័ន្ធ និងភាពអភិវឌ្ឍន៍ចំណេះដឹងបន្ថែម

-មានការយកចិត្តទុកដាក់ខ្ពស់លើ គុណភាព សុវត្ថិភាព និងស្តង់ដារ

-មានគំនិតផ្តួចផ្តើមក្នុងការធ្វើការងារឱ្យប្រសើរឡើងជាបន្តបន្ទាប់

-ត្រូវមានភាពអំណត់ក្នុងការងារ និងធ្វើការស្ថិតនៅក្រោមសម្ពាធ

-មានសមត្ថភាពក្នុងការទំនាក់ទំនងជាភាសាអង់គ្លេស

-មានគំនិតជាអ្នកដឹកនាំ និងគ្រប់គ្រងពេលវេលាបានល្អ

Collection by VCAT Professional Consultant

-មានសមត្ថភាពក្នុងការធ្វើការប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិបទជាក្រុម

-យកចិត្តទុកដាក់ទៅលើភាពលម្អិត និងភាពត្រឹមត្រូវនៃការងារ

-ផ្តល់អាទិភាពទៅលើអ្នកមាន សញ្ញាបត្រ A+, Network+ ឬសញ្ញាបត្រមានតម្លៃស្មើ

-ផ្តល់អាទិភាពទៅលើអ្នកមានទីលំនៅបច្ចុប្បន្នក្នុងមូលដ្ឋាននៃសាខាខេត្តនីមួយៗ

**កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ**

-មានកំរិតវប្បធម៌យ៉ាងទាប បរិញ្ញាបត្ររង ពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា

-មានបទពិសោធន៍ការងារពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន យ៉ាងតិច ១ឆ្នាំ

-មានចំណេះដឹងភាសាអង់គ្លេស អាចប្រើប្រាស់បាន

**ព័ត៌មាននៃការដាក់ពាក្យសុំបម្រើការងារ**

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ និងមានសមត្ថភាពដូចរៀបរាប់ខាងលើ សូមទាញយកទម្រង់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារ និងប្រវត្តិរូបសង្ខេប តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាន www.tax.gov.kh/recruit យកទៅបំពេញដោយកុំព្យូទ័រ បន្ទាប់មកត្រូវផ្ញើមកវិញ ដោយមានបិទរូបថតបច្ចុប្បន្ន (រូបថតដែលថតថ្មី មិនលើសរយៈពេល បីខែ) និងភ្ជាប់មកជាមួយនូវ ច្បាប់ថតចម្លងសញ្ញាបត្រដែលមាន ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ តាមរយៈ E-mail ដែលមានអាសយដ្ឋាន៖ itst20@tax.gov.kh ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនង នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាន៖ អាគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
ទូរស័ព្ទលេខ៖ ០២៣ ៨៨៦ ៧២៤ រៀងរាល់ម៉ោងធ្វើការ
កាលបរិច្ឆេទឈប់ទទួលពាក្យ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ១៧:០០ នាទី។

**អគ្គនាយកដ្ឋានពន្ធដារ**

Collection by VCAT Professional Consultant

## តារាងបែងចែកចំនួនបុគ្គលិកជាប់កិច្ចសន្យាដែលត្រូវជ្រើសរើស
## ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខេត្ត

**មុខតំណែង៖** មន្ត្រីជំនួយការបច្ចេកទេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT support technician)

| ល.រ | លេខសម្គាល់ | អង្គភាព | ចំនួន (នាក់) |
|---|---|---|---|
| ១ | | អគ្គនាយកដ្ឋានពន្ធដារ - សាខាខណ្ឌ | ១១ |
| ២ | B102 | សាខាពន្ធដារខេត្តបាត់ដំបង | ០១ |
| ៣ | B105 | សាខាពន្ធដារខេត្តកំពង់ស្ពឺ | ០១ |
| ៤ | B108 | សាខាពន្ធដារខេត្តកណ្ដាល | ០១ |
| ៥ | B109 | សាខាពន្ធដារខេត្តកោះកុង | ០១ |
| ៦ | B112 | សាខាពន្ធដារខេត្តព្រះវិហារ | ០១ |
| ៧ | B115 | សាខាពន្ធដារខេត្តរតនៈគិរី | ០១ |
| ៨ | B118 | សាខាពន្ធដារខេត្តស្ទឹងត្រែង | ០១ |
| ៩ | B121 | សាខាពន្ធដារខេត្តឧត្តរមានជ័យ | ០១ |
| ១០ | B123 | សាខាពន្ធដារខេត្តប៉ៃលិន | ០១ |
| | | សរុបចំនួន | ២០ |

Collection by VCAT Professional Consultant